# ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា
# សាលាបឋមសិក្សា អាប៊ីហ្គែល វ៉ែ (ABIGAIL VARE )
# 1198 S. 5th STREET
# PHILADELPHIA, PENNSYLVANIA 19147

# កូនសៀវភៅសម្រាប់ក្រុមគ្រួសារ
# ឆ្នាំ ២០១៣/២០១៤



# ការសហការគ្នា

## ជួយក្មេង

***ធ្វើកាន់តែច្រើន ទទួលផលកាន់តែច្រើន***

**Joanne M. Capriotti,** នាយកសាលា

**ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា**
**សាលាបឋមសិក្សា អាប៊ីហ្គែល វ៉ែ (ABIGAIL VARE)**

**1198 S. 5th STREET**
**PHILADELPHIA, PENNSYLVANIA 19147**

**Joanne M. Capriotti,** នាយិកាសាលា

**ទូរស័ព្ទ៖ ២១៥-៩៥២-៨៦២០**
**ទូរសារ៖ ២១៥-៩៥២-៨៥០៨**

ខែកញ្ញា ឆ្នាំ២០១៣

ជូនចំពោះក្រុមគ្រួសារ៖

តាំងនាមឲ្យសមាជិកបុគ្គលិករបស់យើង នាងខ្ញុំមានសេចក្ដីរីករាយក្នុងការស្វាគមន៍លោកអ្នកមកសាលាបឋមសិក្សា វ៉ែ។ ឆ្នាំនេះជាការចាប់ផ្ដើមថ្មីសម្រាប់ក្រុមគ្រួសារនៃសាលា អាប៊ីហ្គែល វ៉ែ និង ជូច វ៉ាស៊ីងតុន។ នៅដើមឆ្នាំនេះ មានលោកអ្នកជាច្រើននាក់បានមកចូលរួមក្នុងការជួបជុំជាមួយបុគ្គលិករបស់យើងខ្ញុំមួយចំនួន និងបានដើរមើលសាលា។ នៅរដូវក្ដៅនេះ យើងបានចំណាយពេលយ៉ាងច្រើនដើម្បីរៀបចំសាលាសម្រាប់ការត្រឡប់ចូលរៀនវិញរបស់សិស្ស។ យើងខ្ញុំរំភើបចិត្តចង់មើលក្រុមគ្រួសារសាលា វ៉ែ របស់យើងរីកចម្រើននៅពេលដែលយើងចាប់ផ្ដើមធ្វើដំណើរថ្មីនេះ។ គ្មានអ្វីប្រសើជាងក្រុមគ្រួសារដែលជិតស្និទ្ធនឹងគ្នានោះទេ។ យើងខ្ញុំរង់ចាំការបង្កើតឲ្យមានភាពជិតស្និទ្ធជាមួយក្រុមគ្រួសារដែលយើងបម្រើ ក្នុងខណៈដែលយើងខិតខំផ្ដល់មូលដ្ឋានដ៏រឹងមាំដល់សហគមន៍នៃអ្នកសិក្សារបស់យើង។

កូនសៀវភៅនេះគឺជាបំណងក្នុងការផ្ដល់ជូនលោកអ្នក នូវព័ត៌មានដែលលោកអ្នកប្រហែលជាត្រូវការនៅពេលដែលកូនលោកអ្នកជាសិស្សនៅសាលាបឋមសិក្សា វ៉ែ។ ក្រៅពីការសច្ចារបស់សាលា វ៉ែ និងកាលវិភាគប្រចាំថ្ងៃ យើងបានដាក់បញ្ចូលការណែនាំ និងការអធិប្បាយអំពីច្បាប់មួយចំនួន របស់ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា និងរបស់សាលាបឋមសិក្សា វ៉ែ។ យើងខ្ញុំទន្ទឹងរង់ចាំការសហការជាមួយលោកអ្នក តទៅមុខទៀត។

យើងខ្ញុំស្វាគមន៍អ្នកមកកាន់អាគាររបស់យើង ហើយសូមឲ្យលោកអ្នកអញ្ជើញទៅកាន់ការិយាល័យសាលា ដើម្បីចុះឈ្មោះ និងទទួលស្លាកសម្រាប់អ្នកមកកាន់សាលា។ ដើម្បីជួយយើងខ្ញុំក្នុងការរក្សាសន្តិសុខ សូមត្រៀមខ្លួនបង្ហាញអត្តសញ្ញាណប័ណ្ណនៅពេលលោកអ្នកមកកាន់អាគាររបស់សាលា។ សូមចាំថា ការរួមសហការអាចធ្វើឲ្យបុគ្គលម្នាក់ៗទទួលផលបានកាន់តែច្រើន (**T**ogether **E**veryone **A**chieves **M**ore)។ សូមចូលរួមជាមួយក្រុមយើងខ្ញុំ!

ដោយសេចក្ដីស្មោះត្រង់ស្មោះ

*Joanne Capriotti*

នាយិកាសាលា

## ការសច្ចារបស់សាលា វ៉េ

ខ្ញុំជាសិស្សនៃសាលា អាប៊ីហ្គែល វ៉េ
សូមធ្វើការសច្ចានៅថ្ងៃនេះ។
ខ្ញុំនៅទីនេះដើម្បីធ្វើកិច្ចការ និងសិក្សា
ព្រមទាំងរីកចម្រើនតាមវិធីផ្ទាល់ខ្លួនរបស់ខ្ញុំ។

ខ្ញុំនឹងគោរពខ្លួនឯងនិងអ្នកដទៃ
ដោយខ្ញុំនឹងខិតខំធ្វើឲ្យបានល្អបំផុតក្នុងមួយថ្ងៃៗ។
អាប៊ីហ្គែល វ៉េ គឺជាកន្លែងសិក្សារបស់យើង។
យើងធ្វើឲ្យថ្ងៃស្អែកកាន់តែប្រសើរឡើង – នៅថ្ងៃនេះ។

**ពណ៌របស់សាលា – ក្រហម និង ស**

**ឯកសណ្ឋានសាលា – ខោ ឬសំពត់ ពណ៌ទឹកប៊ិចចាស់ អាវពណ៌ក្រហម**

**រូបផ្តល់សំណាងឲ្យសាលា – តុក្កតាខ្លាឃ្មុំ**

## កាលវិភាគប្រចាំថ្ងៃរបស់យើង

| | |
|---|---|
| ៧:៤៥– ៨:០៥ | ផ្តល់អាហារពេលព្រឹកនៅក្នុងសាលញ៉ាំបាយថ្ងៃត្រង់។ |
| ៨:១៥ | កណ្តឹងរោទិ៍ សាលាចាប់ផ្តើមរៀន។ ក្មេងត្រូវតម្រង់ជួរនៅពេលកណ្តឹងរោទិ៍។<br>ក្មេងដែលមិនចូលរួមក្នុងកម្មវិធីអាហារពេលព្រឹក មិនត្រូវមកសាលាមុនម៉ោង៨:១០ ទេ។<br>**សិស្សត្រូវគេចាត់ទុកថាមកសាលាមិនទាន់ពេល បើសិនជាពួកគេមិនមកដល់ថ្នាក់រៀននៅម៉ោង ៨:២០។** |
| | អាហារថ្ងៃត្រង់ចែកជាបួនពេល ទៅតាមកម្រិតថ្នាក់។<br>១០:២៥ – ថ្នាក់ទី១ និងថ្នាក់ទី២     ១១:00 – ថ្នាក់មត្តេយ្យ<br>១១:១០ – ថ្នាក់ទី៣ និងថ្នាក់ទី៤     ១២:00 – ថ្នាក់ទី៧ និងទី៨<br>១២:៤០ – ថ្នាក់ទី៥ និងថ្នាក់ទី៦ |
| ២:៥៤ | ចេញពីរៀន។ |

ឲ្យ **សិស្សានុសិស្សទាំងអស់** ចេញទៅទីធ្លាសាលា។ ដើម្បីសុវត្ថិភាព និងសន្តិសុខ សូមអនុញ្ញាតឲ្យគ្រូឲ្យសិស្សបំបែកជួរជាមុនសិន សឹមហៅកូនរបស់លោកអ្នក។ សូមរង់ចាំហួសពីចម្ងាយពាក់កណ្តាលនៃទីធ្លាសាលា។

> **ត្រូវប្រាប់បងប្អូនឲ្យបញ្ជាក់ពីកន្លែងដែលត្រូវជួបគ្នានៅជិតរបង ដើម្បីទទួលប្អូន។ គេមិនអនុញ្ញាតឲ្យសិស្សានុសិស្សចូលក្នុងអាគារវិញទេ នៅពេលគ្រូបានឲ្យក្រុមរបស់ពួកគេចេញហើយ។**

# ការបម្រើផ្សេងៗសម្រាប់សិស្ស

## ការអប់រំកុមារតូចៗ៖  ថ្នាក់មុនមត្តេយ្យ ដល់ ថ្នាក់ទី៣

គោលបំណងនៃការិយាល័យនេះគឺដើម្បីផ្តល់ កម្មវិធី និងសេវា ដែលមានគុណភាពខ្ពស់ និងការអភិវឌ្ឍន៍ដ៏ទូលំទូលាយ ដែលសមស្របសម្រាប់ក្មេងចាប់ពីពេលកើតដល់អាយុប្រាំបីឆ្នាំ។ គោលបំណង និងការយកចិត្តទុកដាក់ នៃកិច្ចការរបស់យើងគឺ ធ្វើយ៉ាងណាឲ្យក្មេងទាំងអស់ដែលរស់នៅក្នុងទីក្រុងហ្វីឡាដែលហ្វ្យា មានសុវត្ថិភាព និងមានសុខភាពល្អ ហើយមកដល់សាលាដោយមានការត្រៀមខ្លួនសម្រាប់សិក្សាជាស្រេច និងមានជោគជ័យ។

### កម្មវិធីមុនថ្នាក់មត្តេយ្យ

ទាំងនេះជាកម្មវិធីសម្រាប់ការរីកចម្រើនដ៏ទូលំទូលាយរបស់ក្មេងដែលមានអាយុពី៣ ដល់៥ឆ្នាំ។ កម្មវិធីទាំងនេះផ្តោតទៅលើក្មេង ដែលខិតខំធ្វើយ៉ាងណាបង្កើនកម្រិតនៃការត្រៀមខ្លួនជាស្រេចដើម្បីចូលរៀនរបស់ក្មេង។ ដោយសារការយកចិត្តទុកដាក់ទាំងនេះ កម្មវិធីទាំងនេះផ្តល់សេវាជាច្រើនសម្រាប់ក្មេងម្នាក់ៗក្នុង ការអប់រំ និងការអភិវឌ្ឍន៍កុមារតូចៗ សុខភាពធ្មេញ សុខភាពខួរក្បាល អាហារដែលមានជីវជាតិ និងការចូលរួម របស់មាតាបិតា។

### ថ្នាក់មត្តេយ្យ

សាលា អាប៊ីហ្គែល វែ រីករាយនឹងផ្តល់ការបង្រៀនថ្នាក់មត្តេយ្យពេញម៉ោងដល់ក្រុមគ្រួសាររបស់យើង។ សិស្សចាប់ផ្តើមរៀននៅម៉ោង៨:១៥ ហើយ ចប់នៅម៉ោង ២:៥៤។ សូមឲ្យមាតាបិតាយកកូនទៅតម្រង់ជួរក្នុងទីធ្លាសាលានៅពេលព្រឹក ហើយ ជួបសិស្សថ្នាក់មត្តេយ្យរបស់ពួកគេនៅក្រៅ ក្នុងទីធ្លាសាលាដដែលនៅម៉ោង ២:៥៤។ **គេប្រគល់សិស្សឲ្យទៅតែមនុស្សពេញវ័យណា ដែលមានឈ្មោះនៅក្នុងបញ្ជីរាយឈ្មោះមាតាបិតា។**

## ការបម្រើផ្នែកសុខភាព

**គិលានុបដ្ឋាយិការបស់សាលាយើងគឺ Ms. Marsha Collier។** គិលានុបដ្ឋាយិកាសាលាវាយតម្លៃស្ថានភាពសុខភាពរបស់សិស្សម្នាក់ៗតាមរយៈការពិនិត្យមើល ការលូតលាស់ ពិនិត្យភ្នែក និងត្រចៀក ប្រវត្តិសុខភាព និងការពិនិត្យសារពាង្គកាយ ដែលចាំបាច់។ មាតាបិតាណាដែលដឹងថាកូនមានបញ្ហាសុខភាព ត្រូវទាក់ទងទៅគិលានុបដ្ឋាយិកាសាលាឲ្យបានឆាប់ តាមការដែលអាចធ្វើទៅបាន។ បន្ទប់សុខភាពស្ថិតនៅជិតការិយាល័យសាលា។ អាចទាក់ទងទៅ Ms. Collier ដោយទូរស័ព្ទទៅការិយាល័យសាលា លេខ ២១៥-៩៥២-៨៦២០ ហើយរង់ចាំស្តាប់ការប្រាប់ឲ្យធ្វើដូចម្តេចទៀត។

## ដំណឹងសម្រាប់សិស្សានុសិស្ស

គេមិនអាចបញ្ជូន ទូរស័ព្ទ និង/ឬ ដំណឹង បន្តទៅឲ្យសិស្សនៅក្នុងម៉ោងរៀនបានទេ ដោយសារសកម្មភាពនេះអាចរំខានដល់ការបង្ហាត់បង្រៀននៅក្នុងថ្នាក់។ បើសិនជាមានភាពអាសន្នធ្ងន់ធ្ងរ ត្រូវទាក់ទងទៅ នាយកសាលា ឬអាគារនុរក្សរបស់សិស្សានុសិស្ស ដើម្បីសុំជំនួយ។

## ថ្នាក់ពិសេសៗ

សិស្សានុសិស្សនៅសាលាបឋមសិក្សា វែ សប្បាយរៀនថ្នាក់ពិសេសៗ ដែលរួមមាន ដន្ត្រី កាយវប្បកម្ម សិល្បៈ វិទ្យាសាស្ត្រផ្នែកកុំព្យូទ័រ និង សុខភាព។  គ្រូបង្រៀនថ្នាក់ទាំងនេះមានវិញ្ញាបនប័ត្របង្រៀនមុខវិទ្យារបស់ពួកគាត់។

## សេវាគាំទ្រសិស្ស

### អង់គ្លេសសម្រាប់អ្នកដែលនិយាយភាសាដ៏ទៃទៀត (ESOL)

កម្មវិធី ESOL គឺជាការបង្ហាត់បង្រៀនអក្សរសាស្ត្រដ៏យកចិត្តទុកដាក់សម្រាប់សិស្សានុសិស្សដែលភាសាអង់គ្លេសមិនមែនជាភាសាពីកំណើត។ គោលបំណងនៃកម្មវិធីនេះគឺដើម្បីឲ្យសិស្សានុសិស្សដែលចេញពីកម្មវិធីនេះ ចេះដឹងភាសាអង់គ្លេសក្នុងកម្រិតដែលពួកគេអាចមានជោគជ័យក្នុងការសិក្សាជាមួយកម្មវិធីធម្មតា។ បច្ចុប្បន្ននេះ សេវា ESOL បានផ្តល់ឲ្យដោយគ្រូបង្រៀនពេញម៉ោងបីនាក់។

### ជំនួយសម្រាប់សិស្សឆ្លាត

កម្មវិធីដែលជួយដល់សិស្សឆ្លាត បម្រើសិស្សានុសិស្សដែលមានប្រាជ្ញា និងមានសមត្ថភាពក្នុងការច្នៃប្រឌិត លើសពីមធ្យមភាគ។ សិស្សដែលមានសិទ្ធិចូលរួមក្នុងកម្មវិធីដែលជួយសិស្សឆ្លាតគឺសម្រេចឡើងដោយក្រុមការងារផ្នែកមុខវិទ្យាចម្រុះ។

### កម្មវិធីអប់រំសិស្សដែលក្រុមគ្រួសារផ្លាស់ប្តូរទីលំនៅដើម្បីការងារ

អនុលោមតាមបទបញ្ជារបស់ រដ្ឋសហព័ន្ធ រដ្ឋ និងតំបន់ ក្រសួងអប់រំជាអ្នកទទួលខុសត្រូវក្នុងការផ្តល់ជំនួយដល់សិស្សដែលមានសិទ្ធិចូលរួមក្នុងកម្មវិធីអប់រំសិស្សដែលក្រុមគ្រួសារផ្លាស់ប្តូរទីលំនៅដើម្បីការងារ។ កម្មវីធីនេះជាអង្គការដែលផ្តល់ប្រាក់ជំនួយដោយរដ្ឋសហព័ន្ធ តាមរយៈក្រសួងអប់រំនៃសហរដ្ឋអាមេរិក ហើយចាត់ចែងដោយ ក្រសួងអប់រំនៃរដ្ឋផិនស៊ីលវេញ៉ា និងក្រុមអន្តរការីតំបន់ ឆេស្ទើ (Chester County Intermediate Unit)។ សិស្សអាចទទួលសេវាអប់រំសម្រាប់សិស្សដែលក្រុមគ្រួសារផ្លាស់ប្តូរទីលំនៅដើម្បីការងារ គឺផ្អែកទៅលើសេចក្តីបញ្ជាក់នៃសិទ្ធិ (Certificate of Eligibility (COE)) ដែលបញ្ជាក់ពីការរើលំនៅឆ្លងកាត់ព្រំដែនក្រសួងអប់រំក្នុងកំឡុងពេល ៣៦ខែកន្លងទៅនេះ ហើយមានបំណងចង់រកការងារផ្នែកកសិកម្មធ្វើបណ្តោះអាសន្ន ឬធ្វើតាមរដូវ។ សិស្សដែលមានសិទ្ធិចូលរួម អាចទទួលសេវាអប់រំបន្ថែមរហូតដល់៣ឆ្នាំ ចាប់ពីថ្ងៃមកដល់ ដែលមានសិទ្ធិទទួល។

### ការអប់រំពិសេស

ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ាផ្តល់ កម្មវិធី និងសេវា អប់រំពិសេស ពេញម៉ោងជាបន្ត។ បើសិនជាលោកអ្នកមានកូនពិការ ឬកូនដែលគិតថា ប្លែកពីធម្មតា សូមទាក់ទងទៅសាលាដើម្បីទទួលព័ត៌មានបន្ថែម។ សិទ្ធិទទួលការអប់រំពិសេស ត្រូវសម្រេចដោយក្រុមការងារមុខវិទ្យាចម្រុះ។

# ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា
# សាលាបឋមសិក្សា អាប៊ីហ្គែល វែ
## ច្បាប់ និងការណែនាំ ផ្សេងៗ

### វត្តមានអវត្តមាន និងការមកទាន់ពេលវេលា របស់សិស្ស

ច្បាប់របស់ក្រសួងអប់រំតម្រូវឲ្យសិស្សដែលមានអាយុត្រូវចូលរៀន ដែលបានចុះឈ្មោះនៅសាលានៃក្រសួង ត្រូវទៅរៀនឲ្យបានទៀងទាត់ ទាន់ម៉ោង និងពេញម៉ោង ដោយយោងទៅតាមច្បាប់របស់រដ្ឋផិនស៊ីលវេញ៉ា។ កម្មវិធីអប់រំដែលផ្តល់ឲ្យដោយក្រសួង គឺរៀបចំឡើងដោយផ្អែកទៅលើវត្តមានរបស់សិស្ស និងការតម្រូវឲ្យមានការបង្ហាត់បង្រៀនជាបន្ត និងការចូលរួមសកម្មភាពនៅក្នុងថ្នាក់រៀន។

ត្រូវយក**លិខិត**ដែល មាតាបិតា/អាណាព្យាបាល បានចុះហត្ថលេខារួចមកសាលា ក្រោយពេលអវត្តមានម្តងៗ បញ្ជាក់ថ្ងៃខែ និងមូលហេតុនៃអវត្តមាន។ អវត្តមាននឹងត្រូវកត់សម្គាល់ថា "**គ្មានមូលហេតុ/unexcused**" បើសិនជា មាតាបិតា/អាណាព្យាបាល **មិនផ្តល់លិខិត ក្នុងកំឡុងពេលបីថ្ងៃ** ចាប់ពីថ្ងៃអវត្តមាន។

**នៅពេលដែលសិស្សអវត្តមានបីថ្ងៃឡើងទៅដោយសារជម្ងឺអ្វីមួយ** ត្រូវយកលិខិតពីវេជ្ជបណ្ឌិត សរសេរអំពីការចាំបាច់ត្រូវព្យាបាលសម្រាប់អវត្តមាននេះ លើកលែងតែនាយកសាលាបានបញ្ជាក់អំពីភាពត្រឹមត្រូវនៃអវត្តមាននេះតាមមធ្យោបាយផ្សេងទៀត។ **គេនឹងចាប់**

**ផ្ដើមវិធីស៊ើបអង្កេតការគេចសាលាដោយស្វ័យប្រវត្ត ចំពោះអវត្តមានខុសច្បាស់ដែលលើសពីបីថ្ងៃ។** នៅពេលណាដែលអាចធ្វើទៅបាន មាតាបិតាត្រូវជម្រាបមកសាលា បើសិនជាសិស្សត្រូវឈប់ជាច្រើនថ្ងៃ។ ត្រូវព្យាយាមធ្វើកិច្ចការដែលមិនទាន់បានធ្វើ ដោយសារជម្ងឺ ឬ អវត្តមានដោយមូលហេតុអ្វីផ្សេង ឲ្យបានរួចរាល់។ **សិស្សានុសិស្សក៏ត្រូវទទួលខុសត្រូវ** ចំពោះកិច្ចការដែលមិនទាន់បានធ្វើ ដោយសារការបញ្ឈប់បណ្ដោះអាសន្ន ឬ ការដាក់ទណ្ឌកម្មអ្វីផ្សេងទៀត។

សិស្សានុសិស្សនឹងត្រូវគេកត់ទុកថាមកយឺតពេល បើសិនជាពួកគេមិននៅក្នុងថ្នាក់រៀននៅម៉ោង ៨:២០។ **ការមករៀនយឺតពេលដោយគ្មានមូលហេតុ** ដែលបណ្ដាលឲ្យសិស្សមិនបានទទួលការបង្ហាត់បង្រៀនពេញមួយថ្ងៃ ឬមួយចំនួន អាចចាត់ទុកថាជាអវត្តមានដោយគ្មានមូលហេតុ។ ជាបន្ថែមទៀត **ការមករៀនយឺតពេលដែលលើសពីបីដងឡើងទៅ នឹងបណ្ដាលឲ្យមានការដាក់ទណ្ឌកម្មក្រោយម៉ោងរៀន។**

## ត្រៀមខ្លួនជាស្រេចសម្រាប់សាលា

មុនពេលកូនលោកអ្នកចេញទៅរៀន សូមជួយមើលពួកគេ ឲ្យដឹងថា សៀវភៅ ខ្មៅដៃ និងកិច្ចការដែលគ្រូឲ្យយកទៅធ្វើនៅផ្ទះ បានដាក់នៅក្នុងសំពៀត សម្រាប់ថ្ងៃនោះ។ ក៏ជាការសំខាន់ដែរ បើសិនជាលោកអ្នកពិនិត្យរកមើលក្នុងសំពៀត នូវវត្ថុផ្សេងៗដែលសិស្សានុសិស្សមិនត្រូវយកមកសាលា ដូចជា ប្រដាប់លេង ទូរស័ព្ទដៃ ។ល។ ក្មេងទាំងអស់ត្រូវមានសំពៀតសម្រាប់ទៅរៀន ឬអ្វីមួយដែលអាចដាក់សៀវភៅ និងអ្វីៗដែលចាំបាច់សម្រាប់ថ្នាក់រៀន។ គ្រូនឹងផ្ដល់បញ្ជីឈ្មោះសម្ភារៈដែលចាំបាច់សម្រាប់ថ្នាក់រៀន។

## ទូរស័ព្ទដៃ

ច្បាប់របស់ក្រសួងអប់រំ ហាមមិនឲ្យមាន និង/ឬ ប្រើ ទូរស័ព្ទដៃ ប៊ីព័រ ភេជ័រ ឬឧបករណ៍អេឡិចត្រូនិចផ្សេងទៀត នៅក្នុងសាលាទេ។ ក្នុងកាលៈទេសៈដែលចាំបាច់ ត្រូវពិភាក្សាជាមួយនាយកសាលា។

## ក្រមសីលធម៌នៃអាកប្បកិរិយាសិស្ស

ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា បានបង្កើត ក្រមសីលធម៌នៃអាកប្បកិរិយាសិស្ស ដែលជាច្បាប់មិនលើកលែងចំពោះទង្វើដែលបណ្ដាលឲ្យមានគ្រោះថ្នាក់ដល់សុវត្ថិភាពរបស់សាលា និង/ឬ រំខានដល់ការអប់រំសម្រាប់ក្មេងឯទៀត។ គេចង់ឲ្យសិស្សសិស្សានុសិស្សដែលទៅរៀននៅសាលាបឋមសិក្សា អាប៊ីហ្គែល វែរ៍ (Abigail Vare) ធ្វើតាមអាកប្បកិរិយាទូទៅនៃច្បាប់របស់ក្រសួង។ គេបានចែកចាយ ក្រមសីលធម៌នៃអាកប្បកិរិយាសិស្ស នៅក្នុងខែកញ្ញា នៃឆ្នាំសិក្សានីមួយៗ។

### ច្បាប់ទី ២៦/ACT 26

សភាររបស់រដ្ឋផិនស៊ីលវេញ៉ាបានអនុម័ត (ច្បាប់ទី ២៦) ដែលតម្រូវឲ្យសាលារដ្ឋទាំងអស់ ធ្វើសកម្មភាពចាំបាច់ក្នុងការដោះស្រាយជាមួយ សិស្សណាដែលមានអាវុធនៅនឹងខ្លួន។ វិធានការទាំងនេះបានតម្រូវដោយ ច្បាប់ទី ២៦ រៀបចំឡើងជាវិធីការពារ ដើម្បីធ្វើយ៉ាងណាឲ្យសាលារដ្ឋទាំងអស់មានសុវត្ថិភាព ដែលសិស្សានុសិស្សទាំងអស់អាចធ្វើអ្វីជាមួយគ្នា ក្នុងបរិយាកាស និងស្ថានភាព ដែលបណ្ដុះការសិក្សា ហើយការពារមិនឲ្យមានអំពើហឹង្សា។

## គ្រឹះមូលដ្ឋាននៃកម្មវិធីសិក្សា

ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា បានបង្កើតគ្រឹះមូលដ្ឋាននៃកម្មវិធីសិក្សា ដោយយោងតាមខ្នាតគំរូរបស់រដ្ឋផិនស៊ីលវេញ៉ា។ គ្រឹះមូលដ្ឋាននៃកម្មវិធីសិក្សា សម្រាប់មុខវិទ្យាដែលសំខាន់ៗ ឥឡូវនេះបានអនុវត្តយ៉ាងពេញលេញ។ កម្មវិធីសិក្សាដែលយោងតាមខ្នាតគំរូបានផ្ដល់ឲ្យគ្រូ និងសិស្សានុសិស្សរបស់គាត់ យល់កាន់តែច្បាស់នូវអ្វីដែលធ្វើឲ្យស្ទាត់ជំនាញនៃកិច្ចការទាំងអស់ នៅសាលា។ សាលាបានផ្ដល់ឲ្យសិស្សានុសិស្សនូវសៀវភៅមេរៀនដ៏ត្រឹមត្រូវ ដើម្បីឲ្យត្រូវតាមគ្រឹះមូលដ្ឋាននៃមុខវិទ្យានីមួយៗ។ **គណកម្មាធិការកែទម្រង់សាលារៀន តម្រូវឲ្យសិស្សម្នាក់ៗទទួលខុសត្រូវក្នុងការថែរក្សាទ្រព្យសម្បត្តិរបស់សាលា និងសៀវភៅមេរៀន សម្ភារៈសិក្សា និងឧបករណ៍ ដែលសាលាផ្ដល់ឲ្យពួកគេ។** សិស្សានុសិស្ស និង/ឬ មាតាបិតារបស់ពួកគេនឹងត្រូវគេពិន័យតាមតម្លៃនៃការបាត់បង់ ឬខូចខាត សៀវភៅនៃរៀន សម្ភារៈ និង/ឬ ឧបករណ៍ ដូចតទៅ៖ ត្រូវឲ្យសងសម្ភារៈ មិនទាន់ឲ្យរបាយការណ៍ពិន្ទុ និង/ឬ បាត់បង់សិទ្ធិ ក្នុងការចូលរួម ដូចជា កីឡា ឬសកម្មភាពក្រៅម៉ោងសិក្សា ផ្សេងៗទៀត។

## ច្បាប់នៃការស្លៀកពាក់

សិស្សានុសិស្សទាំងអស់នៅក្នុងក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា តម្រូវឲ្យស្លៀកពាក់ទៅតាមរបៀបដែលបានអនុម័តដោយសាលានីមួយៗ របស់ពួកគេ។ នៅ **សាលាបឋមសិក្សា អាប៊ីហ្គែល វ៉េ** ឯកសណ្ឋានគឺមាន៖

- ខោ ឬសំពត់ ពណ៌ទឹកប៊ិចចាស់ (ខោវែង ខោខ្លី ខោខ្លីមានសំពត់គ្របពីលើ សំពត់ខ្លី ខោរឹតជើង ឬខោមានខ្សែពាក់លើស្មា)
    - **គេមិនអនុញ្ញាតឲ្យស្លៀក ខោមានហោប៉ៅច្រើន ខោខូវប៊យ ខោអាវកាក់ ឬអាវធំម្យ៉ាង ទេ**
- អាវបើកកឡេវបើពណ៌ក្រហម **ឬ** អាវយឺតរបស់សាលា អាប៊ីហ្គែល វ៉េ
- តម្រូវឲ្យពាក់ស្បែកជើងប៉ាតាកខ្លីពណ៌ស។ គេមិនអនុញ្ញាតឲ្យពាក់ ស្បែកជើងផ្ទាត់ ស្បែកជើងកវែង ស្បែកជើងបាល់ឡេ (ballet flats) ។ល។ ទេ។

### ខែដែលមានធាតុអាកាសក្តៅ – ថ្ងៃទី១ ខែមេសា ដល់ ថ្ងៃទី៣១ ខែតុលា

- សិស្សានុសិស្សអាចស្លៀកខោខ្លីត្រឹមជង្គង់ ពណ៌ទឹកប៊ិចចាស់។
- ក្មេងស្រីអាចស្លៀក ខោវែងត្រឹមកំភួនជើង (capris)។ ខោនោះត្រូវដេរ ហើយគ្មាន បូ ក្លាស់គន្លឹះ ខ្សែ និងអ្វីៗផ្សេងទៀត ទេ។
- នៅតែតម្រូវឲ្យពាក់ស្បែកជើងប៉ាតា។ គេហាមមិនឲ្យពាក់ ស្បែកជើងសង្រែក ស្បែកជើងផ្ទាត់ និងម៉ូដស្រដៀងៗគ្នាផ្សេងទៀត។

### នៅពេលធាតុអាកាសត្រជាក់

- ខោ ឬសំពត់ពណ៌ទឹកប៊ិចចាស់។ បើសិនជាស្លៀក**ខោរឹប**ជាមួយសំពត់ខ្លី ត្រូវស្លៀកពណ៌ស ឬពណ៌ទឹកប៊ិចចាស់ ប្រវែងពេញលេញ ហើយគ្រប់ជើង។
- អាវឯកសណ្ឋានមាន៖
    - អាវបើកក ដៃវែង
    - អាវយឺតកអណ្តើក ពាក់ក្រោមអាវបើកកដៃខ្លី ឬអាវយឺត
    - អាវរងាពណ៌លាត ទឹកប៊ិចចាស់ ឬក្រហម។

**គេមិនអនុញ្ញាតឲ្យពាក់អាវរងាដែលមានមួកគ្របក្បាលនៅក្នុងថ្នាក់ទេ។**

- នៅពេលពាក់**ស្បែកជើងកវែង**មកសាលា គេតម្រូវឲ្យសិស្សានុសិស្សដូរទៅពាក់ស្បែកជើងប៉ាតាវិញនៅពេលចូលដល់ក្នុងអាគារ។

**ថ្នាក់កាយវប្បកម្ម** – សិស្សានុសិស្សត្រូវស្លៀក ខោកៅស៊ូ/ខោខ្លី ពណ៌ទឹកប៊ិចចាស់ និងអាវយឺតរបស់ អាប៊ីហ្គែល វ៉េ។ អាវយឺតអាចទិញនៅសាលា ក្នុងតម្លៃ ៦$។

## សូមកត់សម្គាល់៖ សិស្សានុសិស្សត្រូវស្លៀកពាក់ឯកសណ្ឋាន ទើបអាចចូលរួមក្នុងដំណើរកំសាន្តសិក្សាជាមួយថ្នាក់បាន។

## ការស្នើសុំចេញពីសាលានៅពេលមានអាសន្ន

**ច្បាប់របស់ក្រសួងលេខ ១០៣,៧ រៀបរាប់អំពីការអនុញ្ញាតឲ្យសិស្សចេញក្នុងករណីពិសេស នៅក្នុងថ្ងៃសិក្សា។ ការស្នើសុំដោយមាតាបិតាសម្រាប់ការចេញមុនម៉ោង ក្នុងកំឡុងម៉ោងរៀន អាចស្នើសុំសម្រាប់តែពេលមានអាសន្នតែប៉ុណ្ណោះ។**
សូមណាត់ពេលជួបជាមួយគ្រូពេទ្យ និង/ឬ ពេទ្យធ្មេញ ក្រោយម៉ោងរៀន។ បើចាំបាច់ត្រូវអនុញ្ញាតឲ្យសិស្សចេញក្នុងម៉ោងរៀន សូមធ្វើលិខិតស្នើសុំតាមការសរសេរជាលាយលក្ខណ៍អក្សរទៅឲ្យគ្រូនៅពេលព្រឹក។ មាតាបិតា ឬមនុស្សពេញវ័យជាតំណាង **ដែលមានឈ្មោះនៅក្នុងប័ណ្ណសម្រាប់ទាក់ទងពេលមានអាសន្ន** ត្រូវមកកាន់ការិយាល័យ ផ្តល់អត្តសញ្ញាណប័ណ្ណត្រឹមត្រូវ និងចុះហត្ថលេខាក្នុងបញ្ជី។ បន្ទាប់មក គេនឹងហៅសិស្សមកកាន់ការិយាល័យ។ គេនឹងមិនអនុញ្ញាតឲ្យសិស្សចេញតែឯង ឬឲ្យទៅអ្នកណាម្នាក់ក្រៅពី មាតាបិតា ឬមនុស្សពេញវ័យដែលជាតំណាង នោះទេ។ **នេះជាការអនុវត្តន៍បទបញ្ជារបស់ក្រសួងអប់រំ ដើម្បីឲ្យសិស្សានុសិស្សរបស់យើងមានសុវត្ថិភាព។**

**គេនឹងមិនឲ្យសិស្សានុសិស្សចេញក្រោយម៉ោង ២:១៥ ទេ។** នេះជាពេលដែលរវល់បំផុត ដែលសិស្សានុសិស្សត្រូវចម្លងកិច្ចការដែលគ្រូដាក់ឲ្យយកទៅធ្វើនៅផ្ទះ បំពេញកិច្ចការផ្សេងទៀត និងរៀបចំសម្ភារៈរបស់ពួកគេដើម្បីចេញទៅផ្ទះ។

## ព័ត៌មានសម្រាប់ពេលមានអាសន្ន

ក្នុងមួយឆ្នាំៗ ក្រសួងអប់រំចែកលិខិតផ្តល់ព័ត៌មានសម្រាប់ពេលមានអាសន្ន ដែលអាចឲ្យសាលាទាក់ទងទៅមាតាបិតាបាន ក្នុងគ្រាដែលមានអាសន្ន។ **ជាការសំខាន់ណាស់ដែលសាលាត្រូវមានព័ត៌មាននេះ។** នៅពេលណាសិស្ស ឈឺ ឬមានរបួស គឺជាការសំខាន់ណាស់ដែលយើងខ្ញុំអាចទាក់ទងទៅមាតាបិតា សមាជិកគ្រួសារផ្សេងទៀត ឬអ្នកដែលអាចទាក់ទងទៅបាននៅពេលមានអាសន្ន។ សូមជម្រាបទៅការិយាល័យឲ្យបានដឹង បើសិនជាមានការផ្លាស់ប្តូរលេខទូរស័ព្ទសម្រាប់ភាពអាសន្ន។ ក្នុងគ្រាដែលមានភាពអាសន្នធ្ងន់ធ្ងរ ប៉ូលីសនឹងដឹកសិស្សទៅមន្ទីរពេទ្យដែលនៅជិតជាងគេ។

## សាលាបិទពេលមានអាសន្ន

### ការបិទសាលាពេញមួយថ្ងៃទូទាំងក្រុង

បើសិនជាអគ្គនាយកសាលាផ្តល់មូលហេតុជាមុនថាមិនបើកសាលា នឹងមានការព្យាយាមគ្រប់បែបយ៉ាងដើម្បីផ្សព្វផ្សាយព័ត៌មានអំពីការបិទសាលានៅម៉ោង ៥:០០ ព្រឹក។ ប៉ុស្តិ៍ វិទ្យុ និង ទូរទស្សន៍ នឹងផ្សាយថា ***ហ្វីឡាដែលហ្វ្យា ផប្លិក ស្គូល (Philadelphia's public schools)***។ បើសិនជា **សាលារដ្ឋទូទាំងក្រុងបិទពេញមួយថ្ងៃ** គេនឹងមិនផ្តល់យានជំនិះដល់សិស្សនៃទីក្រុងហ្វីឡាដែលហ្វ្យា ដែលទៅរៀននៅសាលាដែលមិនមែនជាសាលារដ្ឋ ទេ។

**នៅពេលដែលសាលាមិនអាចបើកតាមម៉ោងធម្មតាបាន ហើយបើកយឺតពេល** គេនឹងរៀបចំកាលវិភាគសម្រាប់ការមកដល់យឺតពេល។ ក្នុងករណីនេះ គេនឹងផ្តល់យានជំនិះឲ្យ។

### សាលាបិទនៅពេលថ្ងៃ

បើសិនជាមានធាតុអាកាសមិនល្អ ឬភាពអាសន្នអ្វីផ្សេងទៀត ដែលបណ្តាលឲ្យមានការសម្រេចចិត្តថាបិទសាលាមុនម៉ោងចេញធម្មតា **ជាការសំខាន់ដែលយើងខ្ញុំត្រូវមានព័ត៌មាននៅក្នុងសំណុំឯកសារដែលបញ្ជាក់ឲ្យដឹងថាតើកូនលោកអ្នកត្រូវទៅទីណាបើសិនជាលោកអ្នកមិននៅផ្ទះ។** សូមបំពេញ ហើយប្រគល់ឲ្យគេវិញ នូវលិខិតដែលគេនឹងផ្ញើទៅផ្ទះនៅខែកញ្ញា។

## កម្មវិធីបន្ថែមក្រៅម៉ោងសិក្សា និងកីឡា

ច្បាប់របស់ក្រសួងចំពោះការចូលរួមរបស់សិស្សក្នុងកម្មវិធីបន្ថែមក្រៅម៉ោងសិក្សាទាំងអស់ លើកលែងតែកីឡានៅវិទ្យាល័យ កំណត់ឲ្យមានការតម្រូវសម្រាប់ វិទ្យាទូទៅ វត្តមានអវត្តមាន ភាពជាពលរដ្ឋ និងអាកប្បកិរិយា សម្រាប់ថ្នាក់ទី៥ ដល់ថ្នាក់ទី១២។ **ចំពោះសិស្សថ្នាក់ទី៥ ដល់ថ្នាក់ទី៨** ការតម្រូវសម្រាប់វិទ្យាទូទៅ គឺថាសិស្សណាដែលរៀនធ្លាក់មុខវិជ្ជាពីរ ឬច្រើនជាងនេះ ដែលជួបប្រាំថ្នាក់ក្នុងមួយសប្តាហ៍ គ្មានសិទ្ធិចូលរួមក្នុង កីឡា ឬ កម្មវិធីបន្ថែមក្រៅម៉ោងសិក្សា បានទេ។ **អវត្តមានពីសាលា** នៅថ្ងៃដែលមានកម្មវិធីបន្ថែមក្រៅម៉ោងសិក្សា នឹងបណ្តាលឲ្យសិស្សមិនអាចចូលរួមក្នុងកម្មវិធីនោះបាន។ **អវត្តមានដែលលើសពីបីដងឡើងទៅ** ក្នុងកំឡុងពេលមួយត្រីមាស ធ្វើឲ្យសិស្សគ្មានសិទ្ធិចូលរួមក្នុងកម្មវិធីបន្ថែមក្រៅម៉ោងសិក្សា សម្រាប់រយៈពេលដែលនៅសល់ក្នុងត្រីមាសនោះ និងសម្រាប់ត្រីមាសបន្ទាប់ទៀត។ ការគេចមិនចូលថ្នាក់រៀនក៏រាប់ថាជាអវត្តមានពីសាលាដែរ សម្រាប់អត្តពលកម្ម និងកម្មវិធីបន្ថែមក្រៅម៉ោងសិក្សា។

## ការបម្រើម្ហូបអាហារ

សាលានៅហ្វីឡាដែលហ្វ្យាទាំងអស់ចូលរួមក្នុងកម្មវិធីអាហារថ្ងៃត្រង់ទូទាំងប្រទេស។ កម្មវិធីនេះផ្តល់ **អាហារពេលព្រឹក និងអាហារថ្ងៃត្រង់ ដល់សិស្សានុសិស្សទាំអស់។** សិស្សានុសិស្សនៅសាលាបឋមសិក្សា វ៉ៃ ចូលរួមក្នុង កម្មវិធីផ្តល់អាហារជាសកល (Universal Feeding) ដែលផ្តល់ **អាហារដោយឥតគិតថ្លៃ** ដល់សាលាដែលគេបានកំណត់ទុកជាមុន តាមការណែនាំរបស់រដ្ឋសហព័ន្ធ។

## ច្បាប់នៃការបញ្ចប់ការសិក្សា និងការឡើងថ្នាក់

ក្នុងមួយឆ្នាំៗ ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា រៀបចំ និងចែកចាយ ច្បាប់ថ្មីៗអំពី ការបញ្ចប់ការសិក្សា និងការឡើងថ្នាក់។ **ដើម្បីចូលរួមក្នុងការដើរក្នុងពិធីបញ្ចប់ការសិក្សានៅសាលាបឋមសិក្សា វ៉េ សិស្សានុសិស្សថ្នាក់ទីប្រាំបី ត្រូវទទួលពិន្ទុដែលអាចឡើងថ្នាក់បាន គ្រប់មុខវិជ្ជាសំខាន់ៗទាំងបួន ហើយបានពិន្ទុផ្នែកអាកប្បកិរិយាដែលគួរជាទីពេញចិត្ត នៅពេលគេគិតជាមធ្យមភាគ នៅលើរបាយការណ៍ពិន្ទុចុងក្រោយ។ កិច្ចព្រមព្រៀងរបស់សិស្សលម្អិតអំពីតម្រូវការទាំងនេះ ត្រូវចុះហត្ថលេខាក្នុងខែកញ្ញា នៃឆ្នាំនីមួយៗ។**

## ចំណុចសំខាន់ៗអំពីកិច្ចការដែលគ្រូឲ្យយកទៅធ្វើនៅផ្ទះ

កិច្ចការដែលគ្រូឲ្យយកទៅធ្វើនៅផ្ទះ គឺជាផ្នែកមួយរបស់ការសិក្សា។ គ្រូផ្តល់កិច្ចការដែលគ្រូឲ្យយកទៅធ្វើនៅផ្ទះ បួនយប់ក្នុងមួយសប្តាហ៍។ មាតាបិតាអាចជួយកូនឲ្យធ្វើកិច្ចការដែលគ្រូឲ្យយកទៅធ្វើនៅផ្ទះតាមវិធីដូចតទៅនេះ៖

១. រៀបចំពេលវេលាឲ្យបានទៀងទាត់ និងកន្លែងដែលស្ងាត់មួយ ឲ្យកូនលោកអ្នកធ្វើកិច្ចការ។
២. ឲ្យកូនប្រមូលសម្ភារៈ/ឯកសារ ដែលត្រូវការទាំងអស់ មុននឹងចាប់ផ្តើម។
៣. ធ្វើកាលវិភាគសម្រាប់កិច្ចការដែលគ្រូឲ្យយកមកធ្វើនៅផ្ទះ ដើម្បីជួយកូនឲ្យរៀបចំសម្រាប់កិច្ចការទៅថ្ងៃមុខទៀត។
៤. បើសិនជាកូនលោកអ្នកមានបញ្ហាក្នុងការធ្វើកិច្ចការដែលគ្រូឲ្យយកមកធ្វើនៅផ្ទះ និយាយជាមួយគ្រូរបស់កូនអំពីបញ្ហាទាំងនោះ។
៥. និយាយជាមួយកូនពីយោបល់របស់គ្រូ អំពីកិច្ចការដែលគ្រូឲ្យយកមកធ្វើនៅផ្ទះ។

## ការធ្វើដំណើរកំសាន្តរបស់សាលា

តម្លៃការអប់រំនៃការធ្វើដំណើរកំសាន្តរបស់សាលា និងសុវត្ថិភាពរបស់សិស្ស សំខាន់ជាងអ្វីៗដែលត្រូវយកមកពិចារណាក្នុងការកែលម្អការធ្វើដំណើរកំសាន្តរបស់សាលា។ ការធ្វើដំណើរកំសាន្តទាំងអស់របស់សាលា ត្រូវមានការយល់ព្រមដោយ នាយកសាលា និងអគ្គនាយកប្រចាំតំបន់។ លិខិតអនុញ្ញាតសម្រាប់សិស្សធ្វើដំណើរកំសាន្ត ត្រូវចុះហត្ថលេខាដោយមាតាបិតា ហើយប្រគល់ឲ្យទៅសាលាវិញ មុនពេលធ្វើដំណើរកំសាន្ត។ ក្នុងករណីខ្លះ មាតាបិតាត្រូវបង់ថ្លៃយានជំនិះសម្រាប់ការធ្វើដំណើរកំសាន្ត។ គេតម្រូវឲ្យមានការធានារ៉ាប់រងសម្រាប់កម្មវិធីពិសេសៗនៅក្រៅសាលា សម្រាប់ការធ្វើដំណើរកំសាន្តទៅក្រៅទីក្រុងហ្វីឡាដែលហ្វ្យាទាំងអស់។ **សិស្សានុសិស្សត្រូវស្លៀកពាក់ឯកសណ្ឋាន ទើបអាចចូលរួមបាន។**

## ការបម្រើពិសេសៗ

### ការចាក់ថ្នាំបង្ការរោគរបស់សិស្ស

សិស្សទាំងអស់ត្រូវចាក់ថ្នាំបង្ការរោគឲ្យគ្រប់ចំនួន ឬត្រូវគេលើកលែងឲ្យ មុនពេលចូលរៀននៅ សាលារដ្ឋ សាលាសាសនា ឬសាលាឯកជន ណាមួយនៅក្នុងរដ្ឋផិនស៊ីលវេញ៉ា។ នេះជាការតម្រូវរបស់ ក្រសួងសុខាភិបាលនៃរដ្ឋផិនស៊ីលវេញ៉ា គណកម្មាធិការផ្នែកសុខភាពតំបន់ហ្វីឡាដែលហ្វ្យា និងក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា។ តម្រូវការទាំងនេះការពារសិស្សពីការមានរោគដែលគេអាចការពារបាន និងការពារ បញ្ហាផ្សេងៗផ្នែក សុខភាព និងការអប់រំ។ **មានការលើកលែងសម្រាប់មូលហេតុនៃ សាសនា ឬសុខភាព ដូចតទៅ៖** សិស្សានុសិស្សមិនបាច់ចាក់ថ្នាំបង្ការរោគទេ បើសិនជាមាតាបិតា ឬអាណាព្យាបាល **បដិសេធតាមការសរសេរជាលាយលក្ខណ៍អក្សរ** ចំពោះការចាក់ថ្នាំបង្ការរោគ ដោយសារមូលហេតុ សាសនា/ជំនឿ។ សិស្សានុសិស្សមិនបាច់ចាក់ថ្នាំបង្ការរោគទេ បើសិនជា **គ្រូពេទ្យ ឬអ្នកតំណាង ផ្តល់ការសរសេរជាលាយលក្ខណ៍អក្សរ**ថា ការចាក់ថ្នាំបង្ការរោគអាចប៉ះពាល់ដល់សុខភាពរបស់ក្មេង។ នៅពេលដែលគ្រូពេទ្យបញ្ជាក់ថា ការចាក់ថ្នាំបង្ការរោគលែងប៉ះពាល់ដល់សុខភាពរបស់ក្មេងទៀតហើយ ការលើកលែងការចាក់ថ្នាំបង្ការរោគត្រូវអត់សុពលភាព ហើយក្មេងត្រូវតែចាក់ថ្នាំបង្ការរោគ។

### ការបម្រើផ្នែកសុខភាពនៅសាលា

បុគ្គលិកបម្រើផ្នែកសុខភាពនៅសាលានឹងធ្វើ**ការពិនិត្យភ្នែក**ក្មេងទាំងអស់ជារៀងរាល់ឆ្នាំ **ការពិនិត្យការធំលូតលាស់** ពីរឆ្នាំម្តង និង**ការពិនិត្យសោតវិញ្ញាណ** ឲ្យថ្នាក់មត្តេយ្យ និងថ្នាក់ទី១ ២ ៣ ៦ និងទី៩។ ការ**ពិនិត្យរោគវៀចឆ្អឹងខ្នង**ធ្វើឡើងសម្រាប់សិស្សថ្នាក់ទី៦ និងថ្នាក់ទី៧។

**ការពិនិត្យសារពាង្គកាយ និងប្រវត្តិសុខភាព** តម្រូវឲ្យមាននៅពេលចូលរៀន ហើយតម្រូវឲ្យមានការពិនិត្យម្តងទៀតនៅពេលរៀនថ្នាក់ទី៦ និងទី៩។ មាតាបិតាត្រូវយកកូនទៅជួបគ្រូពេទ្យប្រចាំគ្រួសារដើម្បីធ្វើការពិនិត្យអ្វីៗទាំងនេះ។ វេជ្ជបណ្ឌិតប្រចាំគ្រួសាររបស់លោកអ្នក គឺជាមនុស្សដែលល្អបំផុតក្នុងការពិនិត្យអ្វីទាំងនេះ និងផ្តល់ការថែរក្សាសុខភាពដែលចាំបាច់ទាំងអស់។ បើសិនជាលោកអ្នកត្រូវការជំនួយក្នុងការស្វែងរកវេជ្ជបណ្ឌិតប្រចាំគ្រួសារ មន្ទីរព្យាបាល ឬអ្នកឯកទេស ឬបើសិនជាលោកអ្នកមានការបារម្ភផ្សេងទៀត អំពីសុខភាពរបស់កូនលោកអ្នក សូមទូរស័ព្ទមកគិលានុដ្ឋាកសាលា។ ក្នុងករណីខ្លះ គិលានុដ្ឋាកសាលា ឬគ្រូពេទ្យសាលា នឹងធ្វើការពិនិត្យទៅតាមការណែនាំរបស់ វិជ្ជាស្ថានពេទ្យកុមារអាមេរិក (American Academy of Pediatrics) ដែលតម្រូវឲ្យក្មេងដោះខោអាវចេញ។ គេអាចពិនិត្យអង្គជាតិ នៅពេលមានការពិនិត្យសារពាង្គកាយ។ គេសុំឲ្យមាតាបិតានៅទីនោះ។

**ការពិនិត្យធ្មេញ** តម្រូវឲ្យមានសម្រាប់សិស្សថ្នាក់មត្តេយ្យ ថ្នាក់ទី៣ និងថ្នាក់ទី៧។ មាតាបិតាត្រូវយកកូនទៅជួបគ្រូពេទ្យធ្មេញប្រចាំគ្រួសារ ដើម្បីការពិនិត្យទាំងនេះ។

គិលានុដ្ឋាកសាលាក៏អាចជួយជូន **ព័ត៌មានអំពីការធានារ៉ាប់រងសុខភាព** ដល់លោកអ្នក។ មានការធានារ៉ាប់រងសុខភាពដែលឥតគិតថ្លៃ និងមានតម្លៃថោក ដែលក្រុមគ្រួសាររបស់លោកអ្នកអាចមានសិទ្ធិទទួល។

**ថ្នាំដែល មាន និងគ្មាន វេជ្ជបញ្ជា នៅក្នុងសាលា**

មាតាបិតាណាដែលចង់ឲ្យគេជួយផ្តល់ថ្នាំដែលមានវេជ្ជបញ្ជាទៅកូននៅក្នុងម៉ោងរៀន ត្រូវសួរគិលានុបដ្ឋាកសាលាអំពី "**លិខិតស្នើសុំឲ្យគេផ្តល់ថ្នាំ**" (លិខិត MED-1)។ **ត្រូវបំពេញលិខិតនេះ ហើយចុះហត្ថលេខាដោយ វេជ្ជបណ្ឌិត និងមាតាបិតា របស់ក្មេង។** ពេលដែលគិលានុបដ្ឋាកសាលា មិននៅក្នុងសាលា សមាជិកនៃបុគ្គលិកផ្សេងទៀតដែលធ្លាប់បានហ្វឹកហ្វឺនដោយគិលានុបដ្ឋាក អាចជួយផ្តល់ថ្នាំតាមការណែនាំដែលបានកំណត់ដោយ ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា។

បើសិនជាកូនលោកអ្នកមានបញ្ហាសុខភាពអ្វី ឬលេបថ្នាំដែលមានវេជ្ជបញ្ជា ដោយមូលហេតុអ្វីក៏ដោយ ទោះជាថ្នាំនោះមិនលេបនៅសាលាក៏ដោយ វាជាការសំខាន់ដែលលោកអ្នកត្រូវឲ្យគិលានុបដ្ឋាកសាលាដឹង។ **ថ្នាំដែលគ្មានវេជ្ជបញ្ជា ឬសម្រាប់លេបក្នុងរយៈពេលខ្លី មិនអាចផ្ញើមកសាលាតាមកូន ដោយគ្មានវេជ្ជបញ្ជាពីវេជ្ជបណ្ឌិត ឬលិខិតពីមាតាបិតា បានទេ។**

**ការមានថ្នាំដោយគ្មានការអនុញ្ញាតពីគិលានុបដ្ឋាកសាលា នឹងអាចបណ្តាលឲ្យមានការដាក់វិន័យ។ ការចែកថ្នាំឲ្យសិស្សឯទៀត នឹងត្រូវចាត់ថាជាការបំពានយ៉ាងធ្ងន់ធ្ងរ តាមក្រមសីលធម៌នៃអាកប្បកិរិយាសិស្ស។**

**ការធ្វើបាប និងការមិនមើលថែកុមារ**

ជាច្បាប់របស់ គណកម្មាធិការកែទម្រង់សាលារៀន របស់ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា ថាបុគ្គលិកទាំងអស់ត្រូវដឹង និងធ្វើតាមច្បាប់ការពារកុមាររបស់រដ្ឋផិនស៊ីលវេញ៉ា។ ច្បាប់នេះតម្រូវឲ្យបុគ្គលិករបស់ក្រសួងអប់រំ រាយការណ៍បើមានការមន្ទិលសង្ស័យអំពីការធ្វើបាប និង/ឬ ការមិនមើលថែកុមារ ទៅនាយកសាលា ឬអ្នកទទួលសុខត្រូវរអាគារ ដែលជាអ្នកត្រូវរាយការណ៍ទៅក្រសួងផ្តល់ជំនួយដល់មនុស្សជាតិ។ ការប្រណិប័តន៍តាម ច្បាប់របស់រដ្ឋផិនស៊ីលវេញ៉ា និងច្បាប់របស់ក្រសួងអប់រំ នឹងអាចការពារដល់អ្នកដែលពាក់ព័ន្ធទាំងអស់។

**ជំនួយសម្រាប់ អ្នកគ្មានទីលំនៅ គ្មានជម្រក និងនៅពេលមានគ្រោះអាសន្ន**

ក្មេងដែលគ្មានទីលំនៅ មានសិទ្ធិទៅរៀន។ កម្មវិធីសម្រាប់ក្មេងដែលគ្មានទីលំនៅរបស់ក្រសួងអប់រំ គឺដើម្បីបំបាត់នូវឧបសគ្គដែលរារាំងមិនឲ្យក្មេងដែលគ្មានទីលំនៅ មានជោគជ័យក្នុងការសិក្សា។ ក្មេងដែលក្រុមគ្រួសារក្លាយទៅជាអ្នកគ្មានទីលំនៅ អាចរៀននៅសាលាបច្ចុប្បន្នរបស់ពួកគេ ឬដូរទៅសាលាផ្សេងទៀត បើសិនជាសាលានោះនៅជិតជម្រករបស់ពួកគេ។ សាលាដែលទទួលសិស្ស មិនត្រូវរារាំង ឬពន្យាពេល ដល់ការចុះឈ្មោះក្មេងដែលគ្មានទីលំនៅ ដោយតម្រូវឲ្យមានភស្តុតាងអំពី ទីលំនៅ សំណុំឯកសារចាក់ថ្នាំបង្ការរោគ ឬសំណុំឯកសារសុខភាព នោះទេ។ គេអាចផ្តល់កាក់ជិះ SEPTA ដល់សិស្សដែលគ្មានទីលំនៅណា ដែលរស់នៅចម្ងាយជាងមួយម៉ាយល៍ (mile) ពីសាលា។ ការិយាល័យផ្តល់ជំនួយពិសេស ក៏អាចផ្តល់ ឯកសណ្ឋាន និងសម្លៀកបំពាក់ ដល់សិស្សានុសិស្សទាំងនេះដែរ។

ប្រាក់សម្រាប់ពេលមានអាសន្ន ក៏អាចជួយដល់សិស្សានុសិស្សដែលជួបប្រទះនឹងវិបត្តិអ្វីមួយដែរ។ យើងមិនផ្តល់ប្រាក់សម្រាប់ពេលមានអាសន្នទៅឲ្យក្រុមគ្រួសារទេ។ មានតែសិស្សានុសិស្សដែលទៅរៀននៅសាលារបស់យើងខ្ញុំទើបមានសិទ្ធិទទួល។ វាជាការយល់ខុស ហើយមានមនុស្សជាច្រើន ទូរស័ព្ទមកយើងខ្ញុំកាលពីឆ្នាំកន្លងទៅ អំពីប្រាក់នេះ។ ដើម្បីមានសិទ្ធិទទួលប្រាក់សម្រាប់ពេលមានអាសន្ន សិស្សត្រូវចុះឈ្មោះនៅសាលារដ្ឋក្នុងទីក្រុងហ្វីឡាដែលហ្វ្យា (ថ្នាក់ទី១ ដល់ថ្នាក់ ទី១២) ហើយបង្ហាញថាត្រូវការលុយកាក់ជាបន្ទាន់ ដោយសារមានសេចក្តីលំបាកវេទនាដែលកើតមានឡើងភ្លាមៗ ឬជួបប្រទះនឹងព្រឹត្តិការណ៍ដ៏ធំអ្វីមួយ ដែលជះឥទ្ធិពលអាក្រក់ដល់ក្រុមគ្រួសាររបស់សិស្ស។

**ច្បាប់សម្រាប់យានជំនិះ**

យានជំនិះដោយឥតគិតថ្លៃអាចផ្តល់ឲ្យសិស្សានុសិស្សណាដែលមានសិទ្ធិជិះ ដោយផ្អែកទៅលើលក្ខណៈវិនិច្ឆ័យជាក់លាក់។ លក្ខណៈនៃការដឹកជញ្ជូន (រថយន្តសាលា ឬរថយន្ត SEPTA) ត្រូវសម្រេចដោយសេវាយានជំនិះ រួមជាមួយរដ្ឋបាលសាលា។ សិស្សត្រូវរស់នៅក្នុងទីក្រុងហ្វីឡាដែលហ្វ្យា ហើយត្រូវស្ថិតនៅក្នុងស្ថានភាពត្រូវតាមលក្ខណៈអ្វីមួយដូចខាងក្រោមនេះ៖

១. ត្រូវបានចាត់តាំងដោយ ការិយាល័យផ្តល់ជំនួយពិសេស ថាជាសិស្សរៀនក្នុងថ្នាក់ដែលមានការអប់រំពិសេស ដែលការសិក្សានេះ តម្រូវឲ្យផ្តល់យានជំនិះ ដើម្បីឲ្យសិស្សអាចទៅសាលាបាន។
២. រស់នៅចម្ងាយជាងមួយ ម៉ាយ្ល ពីសាលា ហើយចូលរួមដោយស្ម័គ្រចិត្តក្នុង កម្មវិធីដែលលាយឡំគ្នានៅសាលារបស់ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា។
៣. រៀនថ្នាក់ទី១ ដល់ថ្នាក់ទី៦ ហើយរស់នៅចម្ងាយ មួយម៉ាយ្លកន្លះ ឬឆ្ងាយជាងនេះ ពីសាលាដែលគេបានចាត់ឲ្យទៅរៀន។
៤. រៀនថ្នាក់ទី១ ដល់ថ្នាក់ទី៨ ដែលផ្លូវទៅសាលាត្រូវបានចាត់ទុកថាមានគ្រោះថ្នាក់ដោយក្រសួងយានជំនិះនៃរដ្ឋផិនស៊ីលវេញ៉ា។
៥. ត្រូវបានចាត់តាំងដោយ ការិយាល័យនៃអគ្គនាយក ឲ្យទៅរៀននៅសាលាក្រៅពីសាលាដែលពួកគេត្រូវទៅ ដោយមូលហេតុមានសិស្សច្រើនហួសកម្រិត ហើយត្រូវការយានជំនិះ ដូចការសម្រេចរបស់ការិយាល័យយានជំនិះរបស់ក្រសួង។
៦. តាមសំណូមពររបស់នាយកប្រតិបត្តិ ទៅកាន់គណកម្មាធិការកែទម្រង់សាលារៀន ថាជាសិស្សដែលស្ថិតនៅក្នុងស្ថានភាពពិសេស ដែលតម្រូវឲ្យមានសេចក្តីត្រូវការខុសពីធម្មតា ចំពោះយានជំនិះដែលក្រសួងផ្តល់ឲ្យ។

**សិស្សានុសិស្សដែលជិះរថយន្ត** ត្រូវចូលក្នុងទីធ្លាសាលានៅពេលមកដល់ ហើយទៅតម្រង់ជួរ។ បើសិនជាចូលរួមក្នុងកម្មវិធីអាហារពេលព្រឹក សិស្សដែលជិះរថយន្តត្រូវឆ្ពោះទៅកាន់សាលញ៉ាំអាហារថ្ងៃត្រង់ ដែលមានមនុស្សពេញវ័យជាអ្នកមើលខុសត្រូវ។ ពេលញ៉ាំរួច សិស្សានុសិស្សត្រូវត្រឡប់ទៅទីធ្លាសាលាសម្រាប់ពេលចូលរៀននៅពេលព្រឹក។

**ពេលចេញពីរៀន** សិស្សដែលជិះរថយន្តត្រូវជួបជុំគ្នានៅក្នុងសាលប្រជុំ តាមកន្លែងអង្គុយដែលគេបានកំណត់ឲ្យ ដើម្បីចាំរថយន្តរបស់ខ្លួន។ នៅពេលដែលរថយន្តមកដល់ សិស្សានុសិស្សទាំងអស់ត្រូវឡើងជិះរថយន្ត តាមការចាត់តាំង។ បើសិនជាមានមូលហេតុអ្វីមួយដែលមាតាបិតាមានការរៀបចំផ្សេងទៀតសម្រាប់ការមកទទួលសិស្ស ត្រូវផ្តល់ដំណឹងទៅនាយកសាលា តាមការសរសេរជាលាយលក្ខណ៍អក្សរ។

**បទបញ្ជាសម្រាប់រថយន្តសាលា**

ក. **ត្រូវទៅដល់កន្លែងរថយន្តឈប់ដប់នាទីមុន។** អ្នកមិនត្រូវរត់ទៅជិះរថយន្តទេ។
ខ. **ចាំរថយន្តនៅកន្លែងដែលគេចាត់ឲ្យចាំដោយមានសណ្តាប់ធ្នាប់។** ការរុញច្រានគ្នា ឬការធ្វើឲ្យមានការរំខាន អាចបណ្តាលឲ្យមានរបួស។
គ. **ត្រូវអង្គុយជាបន្ទាន់។** ត្រូវអង្គុយឲ្យស្ងៀមនៅពេលដែលរថយន្តធ្វើដំណើរ ឬនៅពេលអ្នកបើកបររថយន្ត ឬអ្នកមើលខុសត្រូវប្រាប់ឲ្យនៅស្ងៀម។
ឃ. **ឡើងជិះ និងចុះពីរថយន្តតាមទ្វារមុខតែប៉ុណ្ណោះ ហើយនៅ<u>ក្រោយ</u>ពេលដែលរថយន្តឈប់នឹងថ្កល់។** (ក្នុងគ្រាដែលមានអាសន្ន គេអាចបង្គាប់ឲ្យធ្វើអ្វីៗផ្សេងទៀត។)

ង. **ត្រូវរក្សាដៃ និងក្បាល ក្នុងឡានរហូត។** ការចោលរបស់អ្វីមួយ ទោះជាតូចប៉ុណ្ណាក៏ដោយ អាចបណ្តាលឲ្យមានគ្រោះថ្នាក់យ៉ាងធ្ងន់ធ្ងរ។
ច. **រក្សា អាហារថ្ងៃត្រង់ និងចំណី របស់អ្នក រហូតដល់ពេលទៅដល់ទីដៅ។** គេមិនអនុញ្ញាតឲ្យ ញុាំ ឬផឹក នៅក្នុងរថយន្តទេ។
ឆ. **ជៀសវាងការស្រែក និងកសម្លេងឮខ្លាំងៗ អ្វីផ្សេងទៀត។** ក្រៅពីរំខានដល់អ្នកដ៏ទៃ សម្លេងឮខ្លាំងៗអាចរំខានដល់អ្នកបើករថយន្ត ហើយបណ្តាលឲ្យការបើកបររថយន្តគ្មានសុវត្ថិភាព។
ជ. **ចុះពីរថយន្តដោយស្ងៀមស្ងាត់ និងមានសណ្តាប់ធ្នាប់។** ទៅចូលរួមជាមួយសិស្សរួមថ្នាក់ នៅក្នុងទីធ្លាសាលា ឬដើរតម្រង់ទៅថ្នាក់រៀន បើសាលាបានចាប់ផ្តើមរៀនហើយ។
ឈ. **ចូរប្រុងប្រយ័ត្ននៅពេលឆ្លងថ្នល់។** ត្រូវមើលឆ្វេងស្តាំ។
ញ. **យកចិត្តទុកដាក់ដល់ការណែនាំរបស់អ្នកបើករថយន្ត ឬអ្នកមើលខុសត្រូវ។** ពួកគេជាមនុស្សពេញវ័យ ដែលមានការទទួលខុសត្រូវ ហើយបារម្ភអំពីសុវត្ថិភាពរបស់អ្នក។

សូមជ្រាបថា សិស្សានុសិស្សដែលប្រព្រឹត្តល្មើសនឹងបទបញ្ជាទាំងនេះ អាចបាត់បង់សិទ្ធិជិះរថយន្ត មួយរយៈ ឬជាអចិន្ត្រៃ។ (ក្នុងគ្រាដែលសិស្សត្រូវគេដកមិនឲ្យជិះថយន្ត គឺជាការទទួលខុសត្រូវរបស់មាតាបិតាក្នុងការជូនកូន ទៅ និងមកពីសាលា។) សូមរំឮកដល់មាតាបិតាថា តាមច្បាប់របស់រដ្ឋជិនស៊ីលវេញ៉ា គេមិនអនុញ្ញាតឲ្យសិស្សានុសិស្សជិះរថយន្តសាលាដោយគ្មានការអនុញ្ញាត ទេ។

## ការចូលក្នុងតំបន់ហាមឃាត់របស់ក្រសួង

១. ច្បាប់នៃការចូលក្នុងតំបន់ហាមឃាត់ ក្រមនៃច្បាប់របស់ទីក្រុងហ្វីឡាដែលហ្វ្យា វគ្គ ១០-៨២៤ បានអនុម័តដោយក្រុមប្រឹក្សាក្រុង ដើម្បីការពារមិនឲ្យអ្នកដែលគ្មានសិទ្ធិ ចូលក្នុងបរិវេណសាលា។

ខដែលមានចែងអំពីច្បាប់នេះ មានដូចតទៅ៖

ក. គ្មានអ្នកណាម្នាក់អាចចូលក្នុងអាគាររបស់ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យាដោយគ្មានការអនុញ្ញាតពីអ្នកទទួលខុសត្រូវអាគារនោះបានទេ។
ខ. ការមិនបានសុំការអនុញ្ញាតក្នុងរយៈពេលដប់ប្រាំនាទីនៃការចូលក្នុងអាគារ ឬការបង្កើតឲ្យមានចលាចល អាចចាត់ទុកថាជាបទល្មើសនឹងច្បាប់នេះ។
គ. បុគ្គលិក និងសិស្ស របស់ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា មិនអាចចូលក្នុងអាគារដែលគេមិនបានចាត់ឲ្យទៅជាប្រចាំ ដោយគ្មានការអនុញ្ញាតពីអ្នកទទួលខុសត្រូវអាគារ បានទេ។
ឃ. អ្នកដែលល្មើសនឹងច្បាប់នេះ ត្រូវទទួលពិន័យមិនលើសពី ៣០០$ និងជាប់គុកមិនលើសពីកៅសិបថ្ងៃ។
ង. អ្នកដែលគេឃើញនៅក្នុងបន្ទប់ក្រៅពីការិយាល័យ ឬក្នុងរបៀងសាលាដែលមិនស្ថិតនៅចន្លោះទ្វារដែលគេអនុញ្ញាតឲ្យចូល និងការិយាល័យ នឹងត្រូវចាត់ទុកថាល្មើសនឹងច្បាប់នេះ។

២. អ្នកដែលគេសុំឲ្យចាកចេញពីអាគារ ឬអ្នកដែលគេបានផ្តល់លិខិតដេញចេញតាមការសរសេរជាលាយលក្ខណ៍អក្សរ រួមទាំងសិស្សានុសិស្សដែលទទួលវិន័យបញ្ឈប់ជាបណ្តោះអាសន្ន ផ្លាស់ប្តូរពីសាលា ឬបណ្តេញចេញពីក្រសួង អាចត្រូវគេចាប់ខ្លួន និងកាត់ទោសតាមមាត្រានៃការមិនស្តាប់បង្គាប់ ចូលក្នុងតំបន់ហាមឃាត់ នៃច្បាប់ឧក្រិដ្ឋ របស់រដ្ឋជិនស៊ីលវេញ៉ា។

# ទំនាក់ទំនងជាមួយសហគមន៍

**អង្គការ FLEISCHER ART MEMORIAL**

កម្មវិធីសិល្បៈតាមការសហការជាមួយសហគមន៍របស់អង្គការ Fleischer (The Fleischer Community Partnerships in the Arts program) សន្យាថាសហការយ៉ាងជិតស្និតជាមួយសហគមន៍ ដើម្បីផ្តល់កម្មវិធីសិល្បៈដែលមានគុណភាពខ្ពស់ ដែលបញ្ចូលកម្មវិធីសិក្សារបស់ក្រសួងតាមវិធីដែលមានន័យ និងលើកកម្ពស់ ការសិក្សា និងការអនុវត្តន៍ របស់សិស្ស។ តាមរយៈកម្មវិធីសិល្បករ របស់អង្គការ Fleischer សិស្សានុសិស្សរបស់យើងមានឱកាសចូលរួមជាមួយគ្រូបង្រៀនសិល្បៈរយៈពេលប្រាំមួយសប្តាហ៍ ក្នុងកម្មវិធីដែលបានរៀបចំដើម្បីគាំទ្រដល់ផ្នែកអ្វីមួយនៃកម្មវិធីសិក្សា។

**កម្មវិធីរៀនអានរបស់ទីក្រុងហ្វីឡាដែលហ្វ្យ៉ា/PHILADELPHIA READS PROGRAM**

កម្មវិធីរៀនអានរបស់ទីក្រុងហ្វីឡាដែលហ្វ្យ៉ា បង្កើតការសហការរវាង ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា និងក្រុមពាណិជ្ជកម្មដែលនៅជុំវិញក្រុង (ដៃគូដែលមានឥទ្ធិពល/Power Partners)។ សិស្សានុសិស្សសាលា វ៉េ ចូលរួមដោយចាប់ដៃគូជាមួយគ្រូបង្វឹក ដើម្បីរៀនអានក្នុងរយៈពេលប្រហែល ៤៥-៦០ នាទី ក្នុងមួយសប្តាហ៍។ កម្មវិធីនេះមានពីខែតុលា ដល់ខែមិថុនា។ កម្មវិធី ដៃគូដែលមានឥទ្ធិពល របស់យើងរួមមាន ការិយាល័យច្បាប់ សូល យូវីង *(law firm of Saul Ewing)* និងបុគ្គលិករបស់ តុលាការនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា (*The Philadelphia Court of Common Pleas)*។ តាមរយៈកម្មវិធីនេះ សិស្សានុសិស្សរបស់យើងមានឱកាសបណ្តុះចំណូលចិត្តក្នុងការអានទន្ទឹមគ្នានិងការបណ្តុះភាពស្និតស្នាលជាមួយអ្នកជួយណែនាំដែលជាមនុស្សពេញវ័យ។

**មិត្តភ័ក្តក្នុងការអាន**

ឱកាសផ្សេងទៀតដើម្បីឲ្យសិស្សានុសិស្សរបស់យើងមានភាពជិតស្និតជាមួយសមាជិកនៃសហគមន៍ គឺតាមរយៈកម្មវិធីមិត្តភ័ក្តក្នុងការអាន (Reading Buddies Program)។ កម្មវិធីនេះ ផ្តល់ឲ្យសិស្សានុសិស្សរបស់យើងចាប់ដៃគូជាមួយប្រជាពលរដ្ឋ និងបុគ្គលិកមកពី Olde City Presbyterian Apartments។ សិស្សានុសិស្សរបស់យើងធ្វើដំណើរទៅទីនោះមួយអាទិត្យម្តង ដើម្បីចំណាយពេលអាន ៤៥ ទៅ ៦០ នាទី ជាមួយមិត្តរបស់ពួកគេ។